

# ព្រះចន្ទ និងមួកកន្ដឹប

Let's Read

The Asia Foundation



ពួកយើងទាំងអស់គ្នាបានទៅលេងបុណ្យដាសារ៉ា។



ប៉ាទិញវ៉ែនតាដ៏ស្រស់ស្អាតឱ្យឈិនទូ។ ម៉ាក់ទិញមួកកន្តឹប
ពណ៌ខៀវស្រោលឱ្យខ្ញុំ។ ប្អូនស្រីតូចរបស់ខ្ញុំបានស្ករគ្រាប់។



តាមផ្លូវត្រលប់មកផ្ទះ ស្រាប់តែមានខ្យល់បក់យ៉ាងខ្លាំង។ វាបក់បើុងមួកខ្ញុំទៅបាត់។



មួកខ្ញុំបានទៅទើរលើមែកពោធិ៍ធំមួយ។



ខ្ញុំយំខ្លាំងណាស់។ ហើយខ្ញុំមិនព្រមញ៉ាំបាយទេ។



យប់បន្តិច ព្រះចន្ទរះឡើង។ វាសម្លឹងមើលមកមួកខ្ញុំដែលនៅលើដើមពោធិ៍ធំនោះ។



ព្រះចន្ទសាកពាក់មួកខ្ញុំ។ វាញញឹមយ៉ាងរីករាយ។ ខ្ញុំក៏ញញឹម
ដែរ។



ថ្ងៃបន្ទាប់ ពេលចេញពីសាលា ម៉ាក់ឱ្យមួកថ្មីពណ៌ក្រហមដ៏ស្អាត មួយមកខ្ញុំ។ គាត់បាននិយាយថា «ព្រះចន្ទផ្ញើវាមក ឱ្យកូន។»



នៅយប់នោះ ព្រះចន្ទ និងខ្ញុំបានពាក់មួក និងញញឹមទាំងពីរនាក់។ ពួកយើងរីករាយយ៉ាងខ្លាំង។



តើអ្នកគិតថា ព្រះអាទិត្យ ត្រូវការពាក់មួកដែរឬទេ?



ទាយទៅមើលថា ខ្ញុំនឹងពាក់មួកមួយណាថ្ងៃនេះ?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Moon and the Cap*, Published by Pratham Books,  © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Sodany Ouch